# តើមានអ្វីកើតឡើងនៅអំឡុងពេលពិនិត្យសុខភាពរបស់អ្នក?



## អ្នកផ្តល់សេវារបស់អ្នកនឹង៖

- ធ្វើការពិនិត្យសុខភាពរាងកាយ
- ពិនិត្យមើលការលូតលាស់ និងការអភិវឌ្ឍរបស់អ្នក
- សួរនាំអំពីប្រវត្តិសុខភាពនៃគ្រួសាររបស់អ្នក
- ផ្តល់ការចាក់ថ្នាំដែលមានការណែនាំ នៅពេលចាំបាច់
- ពិភាក្សាអំពីសុខភាពធ្មេញ ហើយនៅពេលចាំបាច់ ផ្តល់ជូនការបន្ថែមសារធាតុ ភ្លុយអរដល់អ្នក ក៏ដូចជាជួយស្វែងរកពេទ្យធ្មេញផងដែរ
- ពិនិត្យមើលសុខភាពត្រចៀក និងភ្នែករបស់អ្នក
- សួរនាំអំពីសុខភាពផ្លូវចិត្ត និងសុខុមាលភាពផ្លូវអារម្មណ៍របស់អ្នក និងការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ដើម្បីស្វែងយល់ថាតើអ្នកត្រូវការធនធាន ឬជំនួយគាំទ្រឬអត់
- ពិភាក្សាលើប្រធានបទសុខភាពសំខាន់ៗដូចជា សុខភាពផ្លូវភេទ អាហារូបត្ថម្ភ សុវត្ថិភាព និងការការពារស្បែកពីកម្តៅថ្ងៃ

## អ្នកផ្តល់សេវារបស់អ្នកក៏នឹងពិនិត្យមើលផងដែរលើ៖

- **ជំងឺបាក់ទឹកចិត្ត ជំងឺថប់បារម្ភ និងហានិភ័យនៃការធ្វើអត្តឃាត**
- **ជំងឺរបេង (TB)** ប្រសិនបើស្ថិតក្នុងហានិភ័យ
- **កូលេស្តេរ៉ូល** ប្រសិនបើស្ថិតក្នុងហានិភ័យ
- **ភាពស្លេកស្លាំង** ប្រសិនបើស្ថិតក្នុងហានិភ័យ
- **ជំងឺកាមរោគ (STI)** ប្រសិនបើស្ថិតក្នុងហានិភ័យ
- **បញ្ហាសុខភាព** ឬកង្វល់ផ្សេងទៀតដែលអ្នកមាន

*ខែកុម្ភៈ ឆ្នាំ 2023 សម្រាប់ក្មេងជំទង់ និងមនុស្សពេញវ័យដែលមានអាយុពី 12 ដល់ 21 ឆ្នាំ។*

# ប្រសិនបើអ្នកមានសំណួរ ឬចង់ស្វែងយល់បន្ថែម

**គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់ Medi-Cal របស់អ្នក**
លេខទូរសព្ទមាននៅលើបណ្ណសម្គាល់នៃគម្រោងរបស់អ្នក និងគេហទំព័រនៃគម្រោងរបស់អ្នក ឬចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/mmchpd

**ខ្សែទូរសព្ទជំនួយពីសមាជិករបស់ Medi-Cal**
ទូរសព្ទទៅលេខ **1-800-541-5555** (TDD 1-800-430-7077)
ឬចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/myMedi-Cal

**សុខភាពធ្មេញរបស់ Medi-Cal**
ទូរសព្ទទៅ Smile, California តាមរយៈលេខ **1-800-322-6384**
(TTY 1-800-735-2922)
ឬចូលទៅកាន់គេហទំព័រ smilecalifornia.org ឬ www.dhcs.ca.gov/MCP

**សុខភាពផ្លូវចិត្តឯកទេស**
ទូរសព្ទទៅលេខ **1-888-452-8609**
ដើម្បីសួរនាំអំពីសេវាកម្មសម្រាប់ស្ថានភាពសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ ចូរទាក់ទងគម្រោងសុខភាពផ្លូវចិត្តប្រចាំខោនធីរបស់អ្នកតាមរយៈគេហទំព័រ www.dhcs.ca.gov/CMHP។

**ការប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀន**
ទូរសព្ទទៅមជ្ឈមណ្ឌលធនធានផ្នែកប្រើប្រាសសារធាតុនៃក្រសួងសេវាថែទាំសុខភាព (DHCS) 24/7 តាមរយៈលេខ **1-800-879-2772**
ឬចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/SUD-NETRL

**ជំនួយគាំទ្រក្នុងគ្រាមានវិបត្តិ**
ហៅទៅកាន់ខ្សែទូរសព្ទជាតិផ្នែកបង្ការការធ្វើអត្តឃាតតាមរយៈលេខ **988**
ឬទូរសព្ទទៅលេខ **1-833-317-HOPE** (4673)
សម្រាប់ការប្រឹក្សាអំពីវិបត្តិ CalHOPE ដោយផ្ទាល់ សូមចូលទៅកាន់គេហទំព័រ www.calhopeconnect.org

**សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក**
ទូរសព្ទទៅលេខ **1-888-452-8609**

DHCS | KAISER PERMANENTE
www.dhcs.ca.gov/kidsandteens

1363807925-Kh



# Medi-Cal for Kids & Teens

## សេវាបង្ការ និងព្យាបាលសម្រាប់ក្មេងជំទង់ និងមនុស្សពេញវ័យ រហូតដល់អាយុ 21 ឆ្នាំ



# Medi-Cal ផ្តល់ជូនសេវាកម្មសម្រាប់ក្មេងជំទង់ និងមនុស្សពេញវ័យ រហូតដល់អាយុ 21 ឆ្នាំ

**ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ ហើយបានចុះឈ្មោះក្នុង Medi-Cal អ្នកអាច ទទួលបានការពិនិត្យសុខភាព សេវានិងជំនួយគាំទ្រដែលអ្នកត្រូវការដើម្បីមាន ឬទទួលបានសុខភាពល្អ។**

វាមានសារៈសំខាន់ណាស់ក្នុងការត្រួតពិនិត្យសុខភាពក្នុងមួយឆ្នាំម្តងដើម្បីជួយឱ្យអ្នកមានសុខភាពល្អ ទោះបីជាអ្នកមិនឈឺក៏ដោយ។ ពួកគេអាចបង្ការបញ្ហាសុខភាពហើយស្វែងរក និងដោះស្រាយបញ្ហាទាំងនោះឱ្យបានទាន់ពេលវេលា។



ទោះបីជាអ្នកទើបតែបានពិនិត្យសុខភាពរួចហើយក៏ដោយ អ្នកអាចធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិតរបស់អ្នកបានគ្រប់ពេលដែលអ្នកមានកង្វល់អំពីសុខភាព។

អ្នកក៏គួរទៅជួបពេទ្យធ្មេញរៀងរាល់ 6 ខែម្តងផងដែរ ដើម្បីរក្សាធ្មេញរបស់អ្នកឱ្យមានសុខភាពល្អ។

## រៀបចំគម្រោងពិនិត្យសុខភាពរបស់អ្នក

ទូរសព្ទទៅគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់អ្នក។ ឬទូរសព្ទទៅ ខ្សែទូរសព្ទជំនួយពីសមាជិករបស់ Medi-Cal តាមរយៈលេខ **1-800-541-5555** (TDD 1-800-430-7077)។

អ្នកអាចទទួលបានជំនួយដើម្បី៖

- **ស្វែងរកវេជ្ជបណ្ឌិត** ឬរៀបចំការណាត់ជួប
- **ទទួលបានការធ្វើដំណើរ** ទៅ និងមកពីកន្លែងណាត់ជួបរបស់អ្នក ឬទៅទទួលយកឱសថ បរិក្ខារវេជ្ជសាស្ត្រ និងសម្ភារផ្គត់ផ្គង់
- **ស្នើសុំជំនួយផ្នែកភាសា** នៅកន្លែងណាត់ជួបរបស់អ្នក
- **ស្នើសុំសេវាបកប្រែផ្ទាល់មាត់**

ប្រសិនបើអ្នកត្រូវការខិត្តបណ្ណនេះ ឬសម្ភារ Medi-Cal ផ្សេងទៀតនៅក្នុង **ទម្រង់ជំនួស** ដូចជាពុម្ពអក្សរធំ ទម្រង់អូឌីយ៉ូ ស៊ីឌី ឬអក្សរស្ទាបសម្រាប់ជនពិការ ចូរទូរសព្ទទៅលេខ **1-833-284-0040** ។

# សេវាកម្ម Medi-Cal គឺ ឥតគិតថ្លៃ សម្រាប់ក្មេងជំទង់ និងមនុស្សពេញវ័យភាគច្រើនរហូតដល់អាយុ 21 ឆ្នាំ

រាល់ការថែទាំទាំងអស់ដែលអ្នកត្រូវការគឺឥតគិតថ្លៃទេ លុះត្រាតែអ្នកត្រូវបានគេរកឃើញថាមានចំណែកនៃថ្លៃចំណាយ នៅពេលដែលអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal។ ការថែទាំរួមបញ្ចូលទាំងការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការរោគ ការពិនិត្យ សុខភាព និងការព្យាបាលបញ្ហាសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងធ្មេញ។

### សេវាកម្មសុខភាពផ្លូវភេទអាចរួមមាន៖

- ការប្រឹក្សា និងការអប់រំអំពីផែនការគ្រួសារ
- ការពន្យារកំណើត និងថ្នាំពន្យារកំណើតបន្ទាន់
- សេវារំលូតកូន
- ការធ្វើតេស្ត និងការព្យាបាលជំងឺ STI
- ការធ្វើតេស្តរកមេរោគហ៊ីវ (HIV)
- ការថែទាំដែលបញ្ជាក់ពីយេនឌ័រ

### សេវាកម្មសុខភាពអាកប្បកិរិយាអាចរួមមាន៖

- ការព្យាបាលលក្ខណៈបុគ្គល ជាក្រុម និងលក្ខណៈគ្រួសារ
- សេវាកម្មប្រឹក្សាអំពីវិបត្តិ
- ការគ្រប់គ្រងករណី
- ការប្រើប្រាស់ឱសថសម្រាប់ស្ថានភាពសុខភាពផ្លូវចិត្ត
- ការពិនិត្យមើលជំងឺបាក់ទឹកចិត្ត និងជំងឺថប់បារម្ភ
- សេវាកម្មព្យាបាលការញៀនថ្នាំ និងគ្រឿងស្រវឹង



# Medi-Cal សម្រាប់កុមារ និងក្មេងជំទង់ រ៉ាប់រងលើសេវាកម្មដើម្បីគ្រប់គ្រង និងព្យាបាលបញ្ហាសុខភាព

**ប្រសិនបើវេជ្ជបណ្ឌិតរកឃើញកង្វល់អំពីសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ឬធ្មេញ ដែលត្រូវការការព្យាបាល ឬការគ្រប់គ្រង នោះ Medi-Cal ត្រូវតែផ្តល់ និងរ៉ាប់រងលើការថែទាំដែលចាំបាច់។**

## ការថែទាំងដែរ៉ាប់រងដោយ Medi-Cal សម្រាប់កុមារ និងក្មេងជំទង់៖



- សេវាកម្មសុខភាពផ្លូវកាយ រួមបញ្ចូលការថែទាំបឋម និងការជួបពិនិត្យជាមួយអ្នកឯកទេស
- សេវាព្យាបាលសុខភាពផ្លូវចិត្ត និងការញៀនគ្រឿងញៀន ឬគ្រឿងស្រវឹង រួមទាំងការព្យាបាល
- សេវាពិនិត្យ និងតាមដានសុខភាពធ្មេញ
- សេវាសុខភាពភ្នែក រួមបញ្ចូលទាំងវ៉ែនតា
- សេវាសុខភាពត្រចៀក
- ការធ្វើតេស្ត និងការព្យាបាលជំងឺ COVID-19
- បរិក្ខារវេជ្ជសាស្ត្រ និងសម្ភារផ្គត់ផ្គង់ រួមទាំងបរិក្ខារវេជ្ជសាស្ត្រប្រើបានយូរ
- ការប្រើប្រាស់ឱសថ
- ការធ្វើតេស្តនៅមន្ទីរពិសោធន៍ រួមទាំងការធ្វើតេស្ត STI និងការថែទាំតាមដានដែលចាំបាច់
- សេវាកម្មសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ
- សេវាកម្មព្យាបាលដោយចលនា ដោយការប្រកបកិច្ចការ និងដោយសំដី
- ការពិនិត្យផ្ទៃពោះ
- សេវាសុខភាពតាមផ្ទះ រួមទាំងការថែទាំដោយគិលានុបដ្ឋាយិកា
- ការព្យាបាលនៅមន្ទីរពេទ្យ និងនៅគេហដ្ឋាន
- រាល់សេវាកម្មដែលចាំបាច់ផ្សេងទៀត ដូចដែលអ្នកផ្តល់សេវារបស់អ្នកកំណត់